# ត្រៀមខ្លួនដើម្បីចុះឈ្មោះ និងបោះឆ្នោត



ELECTORAL COMMISSION
TE KAITIAKI TAKE KŌWHIRI

## ហេតុអ្វីត្រូវចុះឈ្មោះបោះឆ្នោត ?

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោត អ្នកនឹងមានសំឡេងមួយនៅក្នុងការបោះឆ្នោតទូទៅ ការបោះឆ្នោតមូលដ្ឋាន និងការបោះឆ្នោតប្រជាមតិ។ ការបោះឆ្នោតគឺជាឱកាសរបស់អ្នកក្នុងការបញ្ចេញសំឡេងអំពីអ្នកដែលតំណាងឱ្យអ្នកលើបញ្ហាដែលអ្នកយកចិត្តទុកដាក់។

**អ្នកអាចប្រាកដថាសំឡេងរបស់អ្នកត្រូវបានស្ដាប់ឮតាមរយៈការចុះឈ្មោះបោះឆ្នោត។**

## តើនរណាអាចចុះឈ្មោះបោះឆ្នោតបាន ?

អ្នកត្រូវតែចុះឈ្មោះប្រសិនបើអ្នក៖

- **មានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ហើយ**
- **អ្នកជាពលរដ្ឋនូវែលសេឡង់ ឬជាអ្នករស់នៅអចិន្ត្រៃយ៍នៃប្រទេសនូវែលសេឡង់ និង**
- **បានរស់នៅក្នុងប្រទេសនូវែលសេឡង់អស់រយៈពេលលើសពីមួយឆ្នាំជាប់ៗគ្នាក្នុងពេលណាមួយក្នុងជីវិតរបស់អ្នក។**

ប្រសិនបើអ្នកជាជនជាតិដើមអូស្ត្រាលី, កោះឃុក ម៉ោរី, ណ្ហូអៀន ឬថូខ្លៅអឺន, អ្នកអាចចុះឈ្មោះបាន ប្រសិនបើអ្នកបានរស់នៅក្នុងប្រទេសនូវែលសេឡង់ជាប់ៗគ្នាអស់រយៈពេល 12 ខែ។

ប្រសិនបើអ្នករស់នៅក្រៅប្រទេស អ្នកអាចចុះឈ្មោះចូលរួមការបោះឆ្នោតទូទៅឆ្នាំ 2023 ប្រសិនបើអ្នក៖

- **ជាពលរដ្ឋនូវែលសេឡង់ ដែលបានរស់នៅក្នុងប្រទេសនូវែលសេឡង់ក្នុងរយៈពេល 6 ឆ្នាំកន្លងមក ឬ**
- **ជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសនូវែលសេឡង់ដែលបានរស់នៅក្នុងប្រទេសនូវែលសេឡង់ក្នុងរយៈពេល 4 ឆ្នាំកន្លងមក។**

បន្ទាប់ពីការបោះឆ្នោតឆ្នាំ 2023 រយៈពេលនេះនឹងផ្លាស់ប្តូរត្រឡប់ទៅជា 3 ឆ្នាំសម្រាប់ពលរដ្ឋនូវែលសេឡង់ និង 12 ខែសម្រាប់អ្នករស់នៅអចិន្ត្រៃយ៍នូវែលសេឡង់។

សម្រាប់គោលបំណងបោះឆ្នោត អ្នករស់នៅអចិន្ត្រៃយ៍គឺជាអ្នកដែលមានសិទ្ធិស្របច្បាប់រស់នៅក្នុងប្រទេសនូវែលសេឡង់ ហើយមិនតម្រូវឱ្យចាកចេញក្នុងរយៈពេលជាក់លាក់ណាមួយឡើយ។ ចំណុចនេះរួមបញ្ចូលនរណាម្នាក់ដែលមានទិដ្ឋាការស្នាក់នៅ។

អ្នកអាចចុះឈ្មោះបាននៅពេលដែលអ្នកមានអាយុ 17 ឆ្នាំ។ នៅពេលអ្នកមានអាយុ 18 ឆ្នាំ អ្នកនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ ហើយអ្នកនឹងអាចបោះឆ្នោតបាន។

## តើខ្ញុំចុះឈ្មោះដោយរបៀបណា ?

ការចុះឈ្មោះ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នកគឺមានភាពងាយស្រួល។ អ្នកអាចៈ

- ចូលទៅកាន់ **vote.nz** រួចប្រើបណ្ណបើកបរក្នុងប្រទេសនូវែលសេឡង់ លិខិតឆ្លងដែននូវែលសេឡង់ ឬអត្តសញ្ញាណដែលបានផ្ទៀងផ្ទាត់ដោយ RealMe ដើម្បីចុះឈ្មោះតាមអ៊ីនធឺណិត
- ហៅទូរសព្ទឥតគិតថ្លៃមកលេខ **0800 36 76 56** ហើយស្នើសុំឱ្យផ្ញើទម្រង់បែបបទមកអ្នក

នៅពេលអ្នកចុះឈ្មោះរួចហើយ ឈ្មោះរបស់អ្នកនឹងបញ្ចូលទៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។ អ្នកត្រូវតែស្ថិតនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ដើម្បីបោះឆ្នោត។

អ្នកត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នករាល់ពេលដែលអ្នកប្តូរទីលំនៅ។

## បារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកឬ ?

ប្រសិនបើអ្នកព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក ឬសុវត្ថិភាពក្រុមគ្រួសាររបស់អ្នក អ្នកអាចដាក់ពាក្យបញ្ចូលទៅក្នុងបញ្ជីសម្ងាត់ដែលមិនចេញផ្សាយជាសាធារណៈ។ យើងនឹងរក្សាព័ត៌មានលម្អិតអំពីការចុះឈ្មោះរបស់អ្នកឱ្យមានសុវត្ថិភាព ហើយយើងនឹងមិនផ្តល់ព័ត៌មានទាំងនោះឱ្យនរណាម្នាក់ឡើយ។

ចូលទៅកាន់ **vote.nz** ឬហៅទូរសព្ទមកលេខ **0800 36 76 56** ដើម្បីទទួលបានព័ត៌មានបន្ថែម និងពាក្យសុំ

## ត្រូវការជំនួយក្នុងការចុះឈ្មោះឬ ?

អ្នកអាចសួរនរណាម្នាក់ដែលអ្នកស្គាល់ ដូចជាមិត្តភ័ក្តិ ឬសមាជិកគ្រួសារ ឬអ្នកអាចសួរក្រុមការងារផ្នែកចុះឈ្មោះរបស់យើង ដើម្បីជួយអ្នកបំពេញទម្រង់បែបបទចុះឈ្មោះរបស់អ្នក ឬបំពេញទម្រង់បែបបទជូនអ្នក។

អ្នកត្រូវចុះហត្ថលេខាលើទម្រង់បែបបទនេះ។

ប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលមិនអាចបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទចុះឈ្មោះរបស់ពួកគេដោយសារតែមានបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត អ្នកអាចជួយពួកគេបាន។

ចូលទៅកាន់ **vote.nz** ដើម្បីស្វែងយល់បន្ថែមអំពីការជួយនរណាម្នាក់ឱ្យចុះឈ្មោះបោះឆ្នោត។

## ចុះឈ្មោះបោះឆ្នោត ប្រសិនបើអ្នកជាជនជាតិកំណើតម៉ោរី

ប្រសិនបើអ្នកជាជនជាតិដើមម៉ោរី ហើយចុះឈ្មោះជាលើកដំបូង អ្នកអាចធ្វើការជម្រើសសំខាន់មួយបាន។ អ្នកត្រូវសម្រេចចិត្តថាតើអ្នកចង់មានឈ្មោះក្នុងបញ្ជីឈ្មោះឆ្នោតមួយណាៈ បញ្ជីឈ្មោះទូទៅ ឬបញ្ជីឈ្មោះសម្រាប់ជនជាតិដើមម៉ោរី។ ជម្រើសរបស់អ្នកប៉ះពាល់ដល់តំបន់បោះឆ្នោតដែលអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតទូទៅ។

ប្រសិនបើអ្នកជ្រើសរើសបញ្ជីឈ្មោះទូទៅ អ្នកនឹងបោះឆ្នោតឱ្យបេក្ខជននៅក្នុងតំបន់បោះឆ្នោតទូទៅ។

ប្រសិនបើអ្នកជ្រើសរើសបញ្ជីឈ្មោះសម្រាប់ជនជាតិដើមម៉ោរី អ្នកនឹងបោះឆ្នោតឱ្យបេក្ខជននៅក្នុងតំបន់បោះឆ្នោតសម្រាប់ជនជាតិម៉ោរី។

អ្នកនឹងបោះឆ្នោតឱ្យបញ្ជីគណបក្សនយោបាយដូចគ្នា មិនថាអ្នកស្ថិតនៅក្នុងបញ្ជីឈ្មោះមួយណានោះទេ។

បញ្ជីឈ្មោះដែលអ្នកជ្រើសរើសអាចប៉ះពាល់ដល់វិធីដែលអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតមូលដ្ឋាន។ ប្រសិនបើអ្នកស្ថិតនៅក្នុងបញ្ជីឈ្មោះសម្រាប់ជនជាតិដើមម៉ោរី ហើយអាជ្ញាធរមូលដ្ឋានរបស់អ្នកមានការិយាល័យ ឬមណ្ឌលបោះឆ្នោម៉ោរី អ្នកនឹងបោះឆ្នោតឱ្យបេក្ខជននៅក្នុងការិយាល័យ ឬមណ្ឌលបោះឆ្នោតម៉ោរី។

អ្នកអាចផ្លាស់ប្តូរបញ្ជីឈ្មោះដែលមានឈ្មោះអ្នកបានគ្រប់ពេល លើកលែងតែក្នុងរយៈពេល 3 ខែមុនការបោះឆ្នោតទូទៅ និងការបោះឆ្នោតមូលដ្ឋាន និងក្នុងកាលៈទេសៈមួយចំនួន មុនការបោះឆ្នោតសភា។

## ចង់បានព័ត៌មានបន្ថែមឬ ?

សម្រាប់ព័ត៌មានបន្ថែមអំពីការចុះឈ្មោះ និងបោះឆ្នោតៈ

- សូមចូលទៅកាន់ **vote.nz**
- ហៅទូរសព្ទទៅលេខ **0800 36 76 56**

ព័ត៌មានអំពីការចុះឈ្មោះ និងការបោះឆ្នោតមានផ្តល់ជូនជាច្រើនភាសាតាមរយៈ **vote.nz**

ELECTORAL COMMISSION
TE KAITIAKI TAKE KŌWHIRI

ROE47 05/23_Khmer